

# ធ្វើការជាមួយអ្នកដែលត្រូវបានគេយកចិត្តទុកដាក់តិចតួច

កុមារគឺជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ការអភិវឌ្ឍសង្គម ប៉ុន្តែនៅពេលដែលកុមារគ្មានលទ្ធភាពទៅសាលារៀន ឬត្រូវបានគេរំលោភបំពាន និងមិនត្រូវបានយកចិត្តទុកដាក់ ក៏ដូចជាការដកយកសិទ្ធិរបស់ពួកគេនោះ វានឹងបង្កើតឲ្យមានផលប៉ះពាល់អវិជ្ជមានទៅដល់ធនធានមនុស្ស។ ដោយសារតែកាលៈទេសៈនេះហើយទើប គម្រោងសម្លេងកុមាររបស់អង្គការអាយស៊ីស៊ី ផ្តោតសំខាន់ក្នុងការបម្រើ និងការពារកុមារ ជាពិសេសកុមារនៅក្នុងសហគមន៍ ដែលពួកគេស្ថិតនៅក្នុងចំណោមមនុស្សដែលត្រូវបានគេយកចិត្តទុកដាក់តិចតួច។ ដោយមានជំនួយពីអង្គការអ៊ីនជីអាក ដែលជាដៃគូរៀនសូត្រ និងជាម្ចាស់ជំនួយសម្រាប់គម្រោងសម្លេងកុមារ ស្ថានភាពកុមារនៅក្នុងសហគមន៍បានផ្លាស់ប្តូរយ៉ាងខ្លាំង ដោយសារតែជំនាញ និងចំណេះដឹងលើសិទ្ធិកុមារ ក៏ដូចជាការការពារកុមារដែលក្រុមការងាររបស់ គម្រោងសម្លេងកុមារ ទទួលបានតាមរយៈការបណ្តុះបណ្តាលជំនាញ និងចំណេះដឹងដែលបានចែករំលែកពីវគ្គបណ្តុះបណ្តាលជាច្រើន ទាំងនៅក្នុងស្រុកនិងអន្តរជាតិអំពីសិទ្ធិកុមារ និងការការពារកុមារ។

អ្វីដែលគម្រោងសម្លេងកុមារ បានសម្រេចយ៉ាងធំធេងនៅក្នុងអំឡុងវដ្តនៃគម្រោងនោះ គឺការបង្កើតគណៈកម្មាធិការការពារកុមារ (គកក) ចំនួន ១៧ នៅខេត្តតាកែវ និងពោធិ៍សាត់។ គកក ត្រូវបានបង្កើតឡើងដើម្បីជួយសម្រួលដល់ការសហការគ្នារវាងអ្នកភូមិតាមរយៈការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិកុមារ និងការការពារកុមារ ហើយក៏លើកទឹកចិត្តដល់ពួកគាត់ឲ្យចូលរួមក្នុងការការពារកុមារនៅក្នុងភូមិផងដែរ។ រហូតមកដល់ពេលនេះ គកក ទាំង១៧ត្រូវបានអនុម័តជាផ្លូវការ (សូមមើលរូបភាពខាងលើ) ដោយអាជ្ញាធរមូលដ្ឋានក្នុងការប្រតិបត្តិការជាអង្គការសហគមន៍នៅតាមភូមិរបស់ពួកគេ។ ឧទាហរណ៍ដ៏ល្អមួយពី គកក គឺក្នុងអំឡុងពេលទិវាសិទ្ធិកុមារអន្តរជាតិ ដែលបានប្រារព្ធធ្វើឡើងដោយអភិបាលខេត្តតាកែវ តំណាងកុមារមកពី គកក ទាំងអស់ ត្រូវបានអញ្ជើញឲ្យចូលរួមដោយមន្ទីរសង្គមកិច្ចខេត្ត ហើយតំណាងកុមារមួយរូបមកពី គកក ត្រូវបានអញ្ជើញឲ្យធ្វើការថ្លែងសុន្ទរកថានៅក្នុងពិធីនេះ ហើយគាត់បានធ្វើការថ្លែងសុន្ទរកថាយ៉ាងក្បោះក្បាយនៅចំពោះមុខអ្នកចូលរួមយ៉ាងច្រើន។ វាពិតជាមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់ គកក ដែលពួកគេត្រូវបានផ្តល់ឱកាសឲ្យធ្វើការថ្លែងសុន្ទរកថានៅថ្ងៃបុណ្យជាតិដ៏ពិសេសមួយនេះ។ ជាមួយនឹងសមិទ្ធិផលទាំងអស់នេះ គកក ទទួលបាននូវការគោរព និងវាយតម្លៃកាន់តែខ្ពស់ពីអ្នកភូមិ និងអាជ្ញាធរមូលដ្ឋាន ហើយក៏បានជំរុញឲ្យក្រុមជំនុំដទៃទៀតចាប់ផ្តើមបង្កើត គកក ចំនួនប្រាំទៀតនៅក្នុងឆ្នាំ២០១៨។

អ្វីដែលក្រុមការងាររបស់គម្រោងសម្លេងកុមារ ចង់បានបន្ទាប់ពីត្រូវបានបញ្ចប់គម្រោងនោះ គឺចង់មើលឃើញការងាររបស់ខ្លួនមាន និរន្តរភាពនៅក្នុងដែនអនុវត្តន៍គម្រោង នេះគឺរាប់បញ្ចូលទាំង គកក ជាក្រុមសង្គមស៊ីវិលដែលមានមូលដ្ឋានជាអចិន្ត្រៃនៅក្នុងភូមិរបស់ខ្លួន ហើយអ្នកភូមិបានយល់ដឹងពីតួនាទី និងការទទួលខុសត្រូវរបស់ គកក ផងដែរ។ គម្រោងសម្លេងកុមារ ក៏ជឿជាក់ដែរថាតួអង្គដទៃទៀត ដូចជាក្រុមជំនុំ គ្រូបង្រៀនសាលារដ្ឋ និងអាជ្ញាធរមូលដ្ឋាន ដែលក្រុមការងាររបស់គម្រោងសម្លេងកុមារ បាននឹងកំពុងធ្វើការជាមួយនឹង បន្តគាំទ្រដោយស្វ័យប្រវត្តិនូវកម្មវិធីការពារកុមារ ដោយសារតែពួកគេនៅតែបន្តដើរតួនាទីយ៉ាងសំខាន់នៅពេលដែលគម្រោងសម្លេងកុមារត្រូវបានបញ្ចប់។ គម្រោងសម្លេងកុមារ រំពឹងថាវិធីសាស្រ្ត KAP"ចំណេះដឹង ឥរិយាបថ និងការអនុវត្ត" ស្តីពីសិទ្ធិ និងការការពារកុមារក្នុងចំណោម តួអង្គទាំងនេះនឹងជួយពួកគេក្នុងការបំពេញតួនាទី និងការទទួលខុសត្រូវរបស់ពួកគេឲ្យកាន់តែមានប្រសិទ្ធភាពក្នុងការបំពេញការងាររបស់ពួកគេ។

នៅពេលគម្រោងសម្លេងកុមារ ត្រូវបានបញ្ចប់នៅចុងឆ្នាំ២០១៨ អាយស៊ីស៊ីមានគោលបំណងរក្សាទំនាក់ទំនងល្អដែលមានស្រាប់មួយនេះជាមួយអ្នកពាក់ព័ន្ធក្នុងមូលដ្ឋាន និងដើម្បីបន្តផ្តល់ការលើកទឹកចិត្តទៅពួកគាត់។ តាមរយៈការធ្វើបែបនេះ អាយស៊ីស៊ី ជឿជាក់ថា អ្នកពាក់ព័ន្ធក្នុងមូលដ្ឋាន នឹងបង្កើននូវតម្លាភាព និងគណនេយ្យភាពសម្រាប់ការងារការពារកុមារនៅក្នុងតំបន់របស់ពួកគេ។ អាយស៊ីស៊ី ក៏ចង់ឃើញការងារនេះ បង្កើតផលជាវិជ្ជមានបន្ថែមទៀតបន្ទាប់ពីគម្រោងសម្លេងកុមារត្រូវបានបញ្ចប់ ហើយក៏ចង់ឃើញ ការងារនេះត្រូវបានចម្លងយកទៅអនុវត្តន៍ នៅក្នុងភូមិ និងឃុំដទៃទៀត។

កាលបរិច្ឆេទ ៖ កក្កដា ២០១៨